# សេចក្ដីសង្ខេប
# មតិយោបល់ របស់អង្គការសង្គមស៊ីវិលលើ
# របាយការណ៍វឌ្ឍនភាព ស្ដីពីការអនុវត្តដំណាក់កាលទី ៤
# នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និង
# សម្រាប់ការរៀបចំច្បាប់ថវិកាឆ្នាំ២០២៧ និងឆ្នាំបន្តបន្ទាប់

ក្រុមការងារថវិកា (BWG) ដែលជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ ធ្វើការលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យថវិកាដោយមានអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (NGO Forum) ជាលេខាធិការដ្ឋានបានរៀបចំឯកសារគោលជំហរមួយ ក្នុងការផ្ដល់មតិយោបល់លើរបាយការណ៍វឌ្ឍនភាព ស្ដីពីការអនុវត្តដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដើម្បីចូលរួមចំណែកក្នុងដំណើរការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៧និងឆ្នាំបន្តបន្ទាប់

មតិយោបល់របស់ក្រុមការងារថវិការបស់អង្គការសង្គមស៊ីវិលផ្ដោតលើ ការបែងចែកថវិកាចំពោះវិស័យសំខាន់ៗ ដូចជាវិស័យអប់រំ ជាពិសេសការអប់រំកុមារតូច និងយុវជន វិស័យសុខាភិបាលសាធារណៈ ការលើកកម្ពស់សមភាពយេនឌ័រ និងសមធម៌សង្គម ការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចគាំពារសង្គម ការវិភាជថវិកា និងការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងចំណូល-ចំណាយ បំណុលសាធារណៈ តាមរយៈប្រសិទ្ធភាពពន្ធដារ និងការប្រមូលចំណូល ការប្រឆាំងអំពើពុករលួយ និងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយនិរន្តរភាព។

**ខាងក្រោមនេះគឺជាមតិយោបល់របស់អង្គការសង្គមស៊ីវិលៈ**

**១. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងជីវភាពប្រជាពលរដ្ឋៈ** អង្គការសង្គមស៊ីវិលកត់សម្គាល់ថា រាជរដ្ឋាភិបាលបានរៀបចំយន្តការ «កម្មវិធីអន្តរាគមន៍គ្រប់ជ្រុងជ្រោយ» ដោយបម្រុងទុកថវិកាប្រមាណ១២៨លានដុល្លារ សម្រាប់ជួយសម្រាលផលប៉ះពាល់សេដ្ឋកិច្ចដល់ប្រជាពលរដ្ឋ ដែលជាការឆ្លើយតបគួរឱ្យកោតសរសើរចំពោះស្ថានភាពនាពេលបច្ចុប្បន្ននេះ។

ទោះជាយ៉ាងណា កំណើនសេដ្ឋកិច្ច (GDP) ឆ្នាំ២០២៦ ត្រូវបានទម្លាក់ចុះពី ៥,០% មកត្រឹម ៤,១% ដោយសារឥទ្ធិពលសង្គ្រាមមជ្ឈិមបូព៌ា វិបត្តិព្រំដែន និងថ្លៃប្រេងកើនឡើង ខណៈអតិផរណាឡើងដល់ ៣,៨% (៤,៥% ក្នុងរយៈពេល៥ខែដើមឆ្នាំនេះ) ដែលប៉ះពាល់ផ្ទាល់ដល់ការចំណាយលើទំនិញផ្សេងៗរបស់ប្រជាពលរដ្ឋ។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលបង្កើនទំហំកញ្ចប់ថវិកាជំនួយសង្គម និងពន្លឿនការអនុវត្ត «កម្មវិធីអន្តរាគមន៍គ្រប់ជ្រុងជ្រោយ» ដល់គ្រួសារក្រីក្រ ជាពិសេសស្ត្រី និងកុមារ ជនមានពិការភាព ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា កម្មករនិយោជិត និងអ្នកប្រកបរបររ៉ឺម៉កកង់បី ដើម្បីការពារពួកគេពីការធ្លាក់ចូលក្នុងភាពក្រីក្រឡើងវិញ និងទទួលបានសេវាសង្គមប្រកបដោយគុណភាព និងបរិយាបន្ន។**

**២. វិស័យអប់រំ៖** អង្គការសង្គមស៊ីវិលសូមស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងឆមាសទី១ ឆ្នាំ២០២៦ ដែលកម្មវិធីអាហារតាមសាលារៀន បានពង្រីកការគ្របដណ្តប់ដល់ ៨១៦សាលារៀនក្នុង១០ខេត្ត ជួយសិស្សប្រមាណ២៣ម៉ឺននាក់ ក៏ដូចជាការខិតខំប្រែក្លាយសាលាគរុកោសល្យទៅជាស្តង់ដារសាលារៀនគំរូ (គ.រ.អ.)។

ទោះជាយ៉ាងណា អតិផរណា (៤,៥%) កំពុងបង្កហានិភ័យឱ្យសិស្សគ្រួសារក្រីក្របោះបង់ការសិក្សាខណៈការប្រែក្លាយសាលាគរុកោសល្យ និងស្តង់ដារសាលារៀនគំរូ (គ.រ.អ.) នៅមានកម្រិត ហើយការបែងចែកថវិកាជាតិសម្រាប់វិស័យអប់រំនៅមិនទាន់គ្រប់គ្រាន់ដើម្បីធានាគុណភាពហេដ្ឋារចនាសម្ព័ន្ធសាលារៀនជនបទ(«សាលារៀនគំរូ») ការអប់រំកុមារតូច មូលដ្ឋានគ្រឹះអាន-គណិតវិទ្យា (Foundational Learning) និងអប់រំវិជ្ជាជីវៈ/សិល្បៈ។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលរក្សាការបែងចែកយ៉ាងហោចណាស់ ២០% នៃការចំណាយជាតិសម្រាប់ការអប់រំ ព្រមទាំង៖ (១) ពង្រីកកម្មវិធីអាហារតាមសាលារៀនឱ្យហួសពី១០ខេត្តគោលដៅ និង (២) ដំឡើងទំហំអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ឱ្យសមស្របនឹងថ្លៃទំនិញបច្ចុប្បន្ន។ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) គួរត្រូវបានតម្រូវឱ្យធ្វើរបាយការណ៍ជាសាធារណៈអំពីវឌ្ឍនភាពនៃការអនុវត្តថវិកា ដោយភ្ជាប់ជាមួយសូចនាករគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM performance score) និងគប្បីឱ្យមានសង្គមស៊ីវិលចូលរួមក្នុងការសិក្សា/ផែនការសកម្មភាព (២០២៦-២០២៨) ដែលភ្ជាប់ទំនាក់ទំនងរវាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគុណភាពសេវាអប់រំ។**

**៣. ថវិកាឆ្លើយតបទៅនឹងយេនឌ័រ និងសមធម៌សង្គម៖** អង្គការសង្គមស៊ីវិលសូមអបអរសាទរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តការគាំទ្រដល់ការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ២០២៤-២០៣៤ និងផែនការយុទ្ធសាស្ត្រ នារីរតនៈទី៦ (២០២៤-២០២៨)។

ទោះជាយ៉ាងណា ការជម្រុញការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងនយោបាយតាមរយៈឱកាសការងារ ការអប់រំ និងការបណ្តុះបណ្តាលជំនាញនៅមិនទាន់ត្រូវបានចាត់ទុកជាអាទិភាពគ្រប់គ្រាន់ខណៈប្រព័ន្ធថវិកាឆ្លើយតបនឹង យេនឌ័រ និងប្រព័ន្ធតាមដាន-វាយតម្លៃ នៅមិនទាន់មានគោលដៅជាក់លាក់ដែលអាចតាមដានបាន។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលជម្រុញការចូលរួមរបស់ស្ត្រីជាអាទិភាព ព្រមជាមួយការបង្កើតប្រព័ន្ធថវិកា ឆ្លើយតបនឹងយេនឌ័រ និងប្រព័ន្ធតាមដាន-វាយតម្លៃ ដើម្បីធានាប្រសិទ្ធភាព និងសមធម៌ក្នុងការអនុវត្ត។ សូមពិចារណាកំណត់គោលដៅជាក់លាក់ផងដែរ ដូចជាភាគរយអប្បបរមានៃថវិកាក្រសួង-ស្ថាប័នដែលត្រូវសម្គាល់ថាឆ្លើយតបនឹងយេនឌ័រ (តាមប្រព័ន្ធ GRB) ឬថវិកាអប្បបរមាសម្រាប់សេវាការពារជនរងគ្រោះអំពើហិង្សាយេនឌ័រ ដើម្បីធ្វើឱ្យសំណើនេះអាចតាមដានបាន ដូចវិស័យអប់រំ (២០%) និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣០%)។**

**៤. ការគាំពារសង្គម និងសុខភាពសាធារណៈ៖** ក្នុងឆមាសទី១ ថវិកាគាំទ្រមូលនិធិសមធម៌សុខាភិបាល មន្ទីរពេទ្យគន្ធបុប្ផា និងការឧបត្ថម្ភមាតុភាព បានបន្តល្អ ដែលជាសញ្ញាវិជ្ជមានចំពោះការការពារសុខភាពប្រជាពលរដ្ឋ។

ទោះជាយ៉ាងណាពលរដ្ឋនៅតាមមូលដ្ឋាននៅតែខ្វះខាតឱសថសំខាន់ៗ ខណៈអត្រាឥណទានមិនដំណើរការ (NPL ៨,៧%) អាចរារាំងក្រុមងាយរងគ្រោះពីការទទួលសេវាសុខភាព។ លើសពីនេះនិយមន័យ «កម្មករក្រៅ

ប្រព័ន្ធ» ក្នុងប្រព័ន្ធ ប.ស.ស./NSSF នៅមានកម្រិតតូចចង្អៀត ចំណែកឯការចំណាយថវិកាជំពូក៦២ ក៏មួយផ្នែកនៅមិនច្បាស់ពីតួនាទី។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលពង្រីកគោលនយោបាយគាំពារសង្គមទៅដល់ កម្មករក្រៅប្រព័ន្ធ មនុស្សចាស់ ស្ត្រី កុមារ ជនពិការ ជនជាតិដើមភាគតិច និងសហគ្រាសមីក្រូ-មធ្យម/កសិករខ្នាតតូច ដោយផ្តល់អាទិភាពសន្តិសុខប្រាក់ចំណូលដល់យុវជន ពលករចំណាកស្រុក និងអ្នកអត់ការងារធ្វើព្រមទាំង៖ (១) ផ្តោតលើកម្មវិធីស្តារនីតិសម្បទាបំណុល (Debt Rehabilitation) និងពង្រីកគាំពារសុខភាពជាសកលដល់កម្មករក្រៅប្រព័ន្ធ (២) បង្កើតយន្តការត្រួតពិនិត្យដោយសហគមន៍ (Community-led Monitoring) លើការផ្គត់ផ្គង់ឱសថ និងវ៉ាក់សាំង (៣) ពន្លឿននីតិវិធីទទួលបណ្ណសមធម៌សុខាភិបាល សម្រាប់កម្មករក្រៅប្រព័ន្ធនិង អ្នកប្រកបរបររ៉ឺម៉កកង់បី ដើម្បីការពារពួកគាត់ពីការចំណាយផ្ទាល់លើសុខភាព (Out-of-pocket Expenditure) និង (៤) ពង្រីកនិយមន័យ «កម្មករក្រៅប្រព័ន្ធ» ក្នុងប្រព័ន្ធ ប.ស.ស./NSSF ឱ្យរួមបញ្ចូលសិប្បករ និង អ្នកប្រកបរបរវប្បធម៌ ព្រមទាំងស្នើសុំឱ្យមានតម្លាភាព និងការចូលរួមរបស់សង្គមស៊ីវិលក្នុងផែនការសកម្មភាព PFM-សុខភាព (២០២៦-២០២៨) ជាពិសេសផ្នែកទាក់ទងនឹងការផ្តល់សេវាសុខភាពដល់ក្រុមងាយរងគ្រោះ។**

**៥. ការវិភាជថវិកា និងការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ៖** អង្គការសង្គមស៊ីវិលសូមស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងការជម្រុញវិមជ្ឈការហិរញ្ញវត្ថុទៅថ្នាក់ក្រោមជាតិ (Objective 34) ក្នុងឆមាសទី១ ឆ្នាំ២០២៦ រួមមាន៖ ការដាក់បញ្ចូលរដ្ឋបាលរាជធានី-ខេត្តចំនួន១៣ដែលនៅសល់ទាំងអស់ចូលរួមក្នុងកម្មវិធីកែទម្រង់ PFMRP ចាប់ពីឆ្នាំ២០២៧ ការរៀបចំក្របខណ្ឌថវិកាឆ្នាំវែង (MTBF) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការដាក់ស្នើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី។

ទោះជាយ៉ាងណាទិន្នន័យឆមាសទី១ ឆ្នាំ២០២៦ បង្ហាញថា អត្រាអនុវត្តចំណាយថវិកាថ្នាក់ក្រោមជាតិសម្រេចបាន ត្រឹមតែ ៤២,៨២% (បើប្រៀបធៀបនឹងអត្រាអនុវត្តថ្នាក់ជាតិ ៤៤,១៥%) ដែលនៅឆ្ងាយពីគោលដៅនៃការចំណាយថវិកាជាតិសរុបទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ភាពយឺតយ៉ាវនេះភាគច្រើនបណ្តាលមកពីការផ្លាស់ប្តូររចនាសម្ព័ន្ធអង្គភាព និងកម្រិតយល់ដឹងក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS នៅមានកម្រិត។ លើសពីនេះលទ្ធភាពការចូលរួមសាធារណជននៅមានកម្រិតក្នុងការចូលទៅកាន់ព័ត៌មានលម្អិតអំពីស្ថាបត្យកម្មប្រព័ន្ធ FMIS ជាពិសេសទិន្នន័យនៃការអនុវត្តថវិកា ហើយសេចក្តីព្រាងច្បាប់ខាងលើក៏មិនទាន់ត្រូវបានបើកឱ្យមានការពិគ្រោះយោបល់ជាសាធារណៈនៅឡើយ។

**អង្គការសង្គមស៊ីវិលសូមស្នើរាជរដ្ឋាភិបាល៖ (១) បន្តគោលដៅបែងចែកយ៉ាងហោចណាស់ ៣0% នៃការចំណាយថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងគុណភាពសេវាសាធារណៈ (២) បង្កើនការបណ្តុះបណ្តាលមន្ត្រីឃុំ-សង្កាត់ស្តីពីលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុព្រមទាំងបើកឱកាសចូលរួមកាន់តែទូលំទូលាយពីពលរដ្ឋ និងអង្គការសង្គមស៊ីវិលមូលដ្ឋានក្នុងការរៀបចំ និងតាមដានថវិកាឃុំ/សង្កាត់ (៣) បើកលទ្ធភាពឱ្យសាធារណជនចូលទៅកាន់ព័ត៌មានសំខាន់ៗ ស្តីពីស្ថាបត្យកម្មប្រព័ន្ធ FMIS របស់កម្ពុជា ជាពិសេសទិន្នន័យអនុវត្តថវិកា និងរបាយការណ៍សរុប តាមរយៈចំណុចប្រទាក់ប្រកបដោយ**

ប្រសិទ្ធភាពជាមួយព័ត៌មានសាធារណៈ (៤) បើកឱកាសឱ្យអង្គការសង្គមស៊ីវិល និងសាធារណៈជនផ្តល់មតិលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មុនពេលដាក់ជូនអនុម័តជាស្ថាពរ និង (៥) ផ្តល់ការបណ្តុះបណ្តាល និង គាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ(ស្រុក/ខណ្ឌ និងឃុំ/សង្កាត់) ក្នុងការអនុវត្តថវិកាដែលបានបែងចែកទៅឱ្យសេវាសង្គម បរិស្ថាន និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពព្រមទាំងការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សផ្នែក PFM ជាទូទៅ នៅតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

**៦. ការគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច៖** រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើនគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម (SMEs) រួមទាំងកម្មវិធីធានាឥណទាន និងវិធានការសម្រួលអាជីវកម្មផ្សេងៗ ដែលជាមូលដ្ឋានល្អសម្រាប់ការពង្រឹងបន្ថែម។ ទោះជាយ៉ាងណាការគាំទ្រទាំងនេះនៅមិនទាន់មានតួលេខ ឬគោលដៅជាក់លាក់ដែលធ្វើឱ្យពិបាកតាមដានលទ្ធផលខណៈ SMEs នៅតែជួបការលំបាកក្នុងការទទួលបានឥណទាន បច្ចេកវិទ្យា និងទីផ្សារអន្តរជាតិ។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលបង្កើនការវិនិយោគគាំទ្រ SMEs តាមរយៈ៖ កម្មវិធីធានាឥណទានសម្រាប់ការផលិត កែច្នៃ និងបង្កើតតម្លៃបន្ថែមផលិតផលកសិកម្ម ការបញ្ចុះពន្ធសម្រាប់អាជីវកម្មដែលមានទំនួលខុសត្រូវចំពោះសង្គម និងបរិស្ថាន ការបណ្តុះបណ្តាលគ្រប់គ្រងអាជីវកម្ម និងបច្ចេកវិទ្យាឌីជីថល និងការភ្ជាប់ទីផ្សារ/ស្តង់ដារ អន្តរជាតិ ដើម្បីពង្រឹងសក្តានុពលភាពប្រកួតប្រជែងរបស់ SMEs និងបង្កើតការងារឱ្យយុវជន និងជនចំណាកស្រុក។ សូមពិចារណាដាក់តួលេខ ឬគោលដៅជាក់លាក់សម្រាប់ មូលនិធិធានាឥណទាន SME (ចំនួនទឹកប្រាក់ ឬភាគរយនៃថវិកាជាតិ) ដើម្បីឱ្យសំណើនេះក្លាយជាការទាមទារច្បាស់លាស់ និងអាចតាមដានលទ្ធផលបាន ដូចវិស័យអប់រំ (២០%) និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣០%)។**

**៧. ប្រសិទ្ធភាពពន្ធដារ និងការប្រមូលចំណូល៖** អង្គការសង្គមស៊ីវិលសូមកត់សម្គាល់ជាវិជ្ជមានចំពោះលទ្ធផលការប្រមូលចំណូលរដ្ឋត្រឹមាសទី២ ឆ្នាំ២០២៦ ដែលសម្រេចបាន ៥២,៧៣% នៃច្បាប់ថវិកា ហើយត្រូវបានព្យាករណ៍ថានឹងសម្រេចប្រមាណ ១០២,៦% នៃគោលដៅប្រចាំឆ្នាំ ដែលបង្ហាញថាមានលំហិរញ្ញវត្ថុ (fiscal space) គ្រប់គ្រាន់សម្រាប់រាជរដ្ឋាភិបាល បង្កើនការវិនិយោគក្នុងវិស័យអប់រំ សុខភាព និងកិច្ចគាំពារសង្គមដូចបានស្នើក្នុងឯកសារនេះ។ អង្គការសង្គមស៊ីវិល ក៏គាំទ្រការដាក់ឱ្យអនុវត្តសាកល្បង E-invoicing System និង Self-service System សម្រាប់អ្នកជាប់ពន្ធផងដែរ។ ទោះជាយ៉ាងណា ការប្រកាសអនុវត្តនីតិកម្មពន្ធដារថ្មីៗ នៅមិនទាន់ត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ SMEs ឱ្យបានទូលំទូលាយគ្រប់គ្រាន់ ដែលអាចនាំឱ្យមានការផាកពិន័យដោយអចេតនា។ លើសពីនេះ ការប្រមូលពន្ធលើរូបវន្តបុគ្គលមានការថយចុះគួរអោយកាត់សំគាល់ ហើយការពឹងផ្អែកខ្លាំងលើពន្ធដកថយ (Regressive Tax) ដូចជា VAT បង្កបន្ទុកធ្ងន់ជាងលើអ្នកមានចំណូលទាប។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលបង្កើនយុត្តិធម៌ តម្លាភាព និងប្រសិទ្ធភាពនៃការប្រមូលចំណូល ដោយបង្កើនពន្ធលើផលិតផលបង្កគ្រោះថ្នាក់ដល់សុខភាព (ភេសជ្ជៈមានជាតិស្ករ គ្រឿងស្រវឹង ថ្នាំជក់) និងបន្ថយពន្ធលើទំនិញចាំបាច់ (ប្រេងឥន្ធនៈ) ព្រមទាំងបន្តជម្រុញពន្ធកំណើន (Progressive Tax) ជាពិសេសលើពន្ធលើ**

ប្រាក់បៀវត្សរ៍ (០-២០% តាមកម្រិតចំណូល) និងពន្ធលើរូបវន្តបុគ្គល ជំនួសការពឹងផ្អែកលើពន្ធដកថយ (Regressive Tax) និងលើកលែងពន្ធលើសម្ភារៈជំនួយជនមានពិការភាព និងមនុស្សចាស់។ ស្នើឱ្យផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីនីតិកម្មពន្ធដារថ្មីៗ ដល់ SMEs ឱ្យបានទូលំទូលាយ ដើម្បីជៀសវាងការផាកពិន័យ ដោយអចេតនា។

**៨. ការប្រឆាំងអំពើពុករលួយ៖** អង្គការសង្គមស៊ីវិលសូមស្វាគមន៍ចំពោះការពង្រឹងការផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈជាមុននៅថ្នាក់ជាតិ (National-Level Proactive Procurement Information Disclosure) ក៏ដូចជាការពង្រឹងការិយាល័យថវិកាសភាឱ្យមានលក្ខណៈស្វយ័ត និងការប្រើប្រាស់បច្ចេកវិទ្យាប្រឆាំងអំពើពុករលួយ។

ទោះជាយ៉ាងណាការផ្សព្វផ្សាយកិច្ចសន្យាលទ្ធកម្មសាធារណៈជាមុននៅថ្នាក់ក្រោមជាតិនៅមិនទាន់មានលក្ខណៈទូលំទូលាយដូចថ្នាក់ជាតិ ចំណែកឯការបង្ហាញជាសាធារណៈនូវការវាយតម្លៃផលប៉ះពាល់បរិស្ថាននៃគម្រោងផ្សេងៗ ក៏នៅមានកម្រិត។

**អង្គការសង្គមស៊ីវិលស្នើសុំការផ្សព្វផ្សាយកិច្ចសន្យាលទ្ធកម្មសាធារណៈជាមុន (Proactive Disclosure)តាមរយៈគេហទំព័រ បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយប្រពៃណី ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបង្ហាញជាសាធារណៈនូវកិច្ចសន្យា/ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងបន្តពង្រឹងគោលនយោបាយមិនអត់ឱនចំពោះអំពើពុករលួយ តម្លាភាពនៃដំណើរការលទ្ធកម្មសាធារណៈ សវនកម្មឯករាជ្យ និងការត្រួតពិនិត្យរបស់សភាដើម្បីធានាគណនេយ្យភាព។**

**៩. ការគ្រប់គ្រងបំណុលសាធារណៈ៖** អង្គការសង្គមស៊ីវិលសូមកត់សម្គាល់ជាវិជ្ជមានចំពោះវឌ្ឍនភាពនៃការគ្រប់គ្រងបំណុលសាធារណៈក្នុងឆមាសទី១ ឆ្នាំ២០២៦រួមមាន៖ ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ និងបានដាក់ស្នើទៅកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធ ការបន្តរក្សាសូចនាករគន្លឹះទាំង៥ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតក្នុងកម្រិតកំណត់ ការអភិវឌ្ឍប្រព័ន្ធរាយការណ៍បំណុល ការចេញផ្សាយសៀវភៅព័ត៌មានស្ថិតិបំណុលសាធារណៈកម្ពុជាលេខ៣០ និងការរៀបចំក្របខណ្ឌលក្ខន្តិកៈសញ្ញាប័ណ្ណនិរន្តរភាព (Sustainable Bond Framework) ដែលបង្ហាញថាបំណុលសាធារណៈកម្ពុជាបន្តត្រូវបានគ្រប់គ្រងបានល្អតម្លាភាព និរន្តរភាព និងប្រសិទ្ធភាព។

ទោះជាយ៉ាងណា រាជរដ្ឋាភិបាលគួរប្រុងប្រយ័ត្នខ្ពស់ចំពោះកម្ចីដែលអាចប៉ះពាល់សេដ្ឋកិច្ចជាតិ និងជីវភាពប្រជាពលរដ្ឋ ដោយប៉ាន់ប្រមាណឱ្យច្បាស់លាស់នូវសមត្ថភាពចំណូល-ចំណាយ និងសមត្ថភាពសងត្រឡប់ ព្រមទាំងផ្តោតការខ្ចីប្រាក់លើគម្រោងផ្តល់អត្ថប្រយោជន៍ច្បាស់លាស់ដល់ក្រុមងាយរងគ្រោះ។ សៀវភៅព័ត៌មានស្ថិតិបំណុលគប្បីចេញផ្សាយឱ្យទាន់ពេលជាងមុន (បច្ចុប្បន្នយឺតយ៉ាវប្រមាណ១ត្រីមាស) ហើយសាធារណជននៅមិនទាន់មាន«ថវិកាសម្រាប់ប្រជាពលរដ្ឋ» ជាភាសាងាយយល់ដើម្បីជួយតាមដាន និងបកស្រាយស្ថានភាពបំណុលជាតិ។ លើសពីនេះបំណុលគ្រួសារនៅមិនទាន់ត្រូវបានតាមដានជាប្រព័ន្ធ ខណៈអត្រាឥណទានមិនដំណើរការ (NPL) លើឥណទានប្រើប្រាស់/មីក្រូហិរញ្ញវត្ថុ បច្ចុប្បន្នស្ថិតនៅ ៨,៧%។

**អង្គការសង្គមស៊ីវិលស្នើឱ្យរាជរដ្ឋាភិបាលៈ (១) ចេញផ្សាយសៀវភៅព័ត៌មានស្ថិតិបំណុលឱ្យទាន់ពេលជាងមុន (២) រៀបចំ «ថវិកាសម្រាប់ប្រជាពលរដ្ឋ» ជាភាសាងាយយល់ស្តីពីស្ថានភាពបំណុលជាតិ (៣) បង្កើនការតាមដានបំណុលគ្រួសារដោយប្រើសូចនាករជាក់លាក់ដូចជា អត្រាបំណុលគ្រួសារធៀបនឹងចំណូល/GDP ឬអត្រាឥណទានមិនដំណើរការ (NPL) លើឥណទានប្រើប្រាស់/មីក្រូហិរញ្ញវត្ថុ និង (៤) បើកឱកាសឱ្យអង្គការសង្គមស៊ីវិល និងសាធារណជនចូលរួមផ្តល់មតិលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ក្នុងអំឡុងពេលនៃការពិគ្រោះយោបល់បច្ចេកទេសជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដែលកំពុងដំណើរការ។**

**១០. ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការរៀបចំផែនការ និងការអនុវត្តកម្មវិធីកែទម្រង់ PFMRP៖** អង្គការសង្គមស៊ីវិលសូមកោតសរសើរដល់ស្មារតីបើកទូលាយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការចែករំលែករបាយការណ៍វឌ្ឍនភាព PFMRP ជាទៀងទាត់ និងការសហការជាមួយដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីកែទម្រង់។

ទោះជាយ៉ាងណា អង្គការសង្គមស៊ីវិលនៅមិនទាន់មានឱកាសចូលរួមជាផ្លូវការគ្រប់គ្រាន់ក្នុងការកំណត់អាទិភាព និងលំដាប់នៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងក្របខណ្ឌ CAP4+3 សម្រាប់រយៈពេលឆ្នាំ២០២៨-២០៣០ ដែលកំពុងត្រូវបានរៀបចំ។

**អង្គការសង្គមស៊ីវិលស្នើសុំចូលរួមក្នុងការកំណត់អាទិភាព និងលំដាប់នៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងក្របខណ្ឌ CAP4+3 សម្រាប់រយៈពេលឆ្នាំ២០២៨-២០៣០ ព្រមទាំងស្នើសុំចូលរួមតាមដាន និងផ្តល់មតិព័ត៌មានត្រឡប់ដល់ក្រសួងបច្ចេកទេសនានា ស្តីពីការអនុវត្តផែនការសកម្មភាព PFMRP របស់ខ្លួន ព្រមទាំងជួយចែករំលែកមេរៀន និងបញ្ហាប្រឈមក្នុងការសម្រេចគោលដៅឆ្នាំ២០២៧។**